# ការអនុវត្តន៍ល្អ
## សំភារៈអនាម័យត្រឹមត្រូវ

**រោងចក្រ កាន់តែប្រសើរ** នៅកម្ពុជា

អនាម័យមិនល្អនៅតាមរោងចក្រ ដែលទទួលឥទ្ធិពលពីភាពមិនសមរម្យនៃបង្គន់ និងកង្វះខាតសំភារៈអនាម័យផ្សេងៗ គឺជាប្រភពសំខាន់មួយនៃសុខភាពមិនល្អក្នុងជួរកម្មករ ។ ដូច្នេះ ភាពមិនសមរម្យនៃសំភារៈអនាម័យអាចជាឧបសគ្គធ្ងន់ធ្ងរដល់ផលិតភាពការងារ ។ ដើម្បីធានាឱ្យមានកំរិតអនាម័យមួយគ្រប់គ្រាន់ បង្គន់ និងសំភារៈអនាម័យផ្សេងៗទៀតក្នុងរោងចក្រ ត្រូវមានគុណភាពសមរម្យ ត្រូវស្តុកឱ្យបានល្អ ស្អាត និងថែរក្សាជាប្រចាំ ។

### ការអនុវត្តន៍ល្អសំរាប់សំភារៈអនាម័យត្រឹមត្រូវ

- កម្មករត្រូវទទួលបានការប្រើប្រាស់បង្គន់ ដោយគ្មានការរឹតត្បិតណាមួយដែលមិនមានហេតុផលឡើយ (រូបភាពទី ១) ។
- បង្គន់គួរតែមាននៅតាមជាន់នីមួយៗ និងសង់ក្នុងទីធ្លារោងចក្រ (រូបភាពទី ១ និងទី ២) ។
- បុរស និងស្ត្រីគួរតែមានបង្គន់ផ្សេងពីគ្នា (រូបភាពទី ១ និងទី ២) ។
- រោងចក្រដែលមានកម្មករស្រីលើសពី ១០០ នាក់ ត្រូវតែមានប្រភេទបង្គន់អង្គុយមួយសំរាប់រាល់ស្ត្រី ៥០ នាក់ (រូបភាពទី ៣) ។
- បង្គន់គួរតែដាក់សាប៊ូ មានទឹក និងមានក្រដាសអនាម័យគ្រប់គ្រាន់ ដើម្បីធានាការប្រើប្រាស់តាមលក្ខណៈអនាម័យល្អ ។
- កំរាលឥដ្ឋនៅក្នុងបន្ទប់ទឹកគួរតែស្អាត និងមានផ្ទៃដែលមិនរអិល ។


រូបភាពទី១


រូបភាពទី២


រូបភាពទី៣

### អត្ថប្រយោជន៍:

- ✓ មានសំភារៈអនាម័យសមរម្យ និងស្អាត ចូលរួមវិភាគទានក្នុងការកាត់បន្ថយការឈឺ និងភាពអវត្តមានរបស់កម្មករ
- ✓ ការផ្តល់បង្គន់ និងសំភារៈអនាម័យផ្សេងៗអាចនាំឱ្យមានសីលធម៌វិជ្ជមានក្នុងជួរកម្មករ ដែលវាចូលរួមចំណែកបង្កើនផលិតភាព

### តាមរបៀបណា:

- ✓ បង្គន់គួរតែសំអាតជាប្រចាំ (យ៉ាងហោចណាស់ម្តងក្នុងមួយថ្ងៃ)
- ✓ បង្គន់គួរតែអាចមានគន្លឹះបិតទ្វារខាងក្នុង មានភ្លើងបំភ្លឺត្រឹមត្រូវ មានកំរាលឥដ្ឋ និងជញ្ជាំងជិត និងមានប្រពន្ធ័លូត្រឹមត្រូវ
- ✓ ផ្តល់សំភារៈសំរាប់ឱ្យកម្មករលាងសំអាតដៃរបស់គេ
- ✓ ធានាថាសាប៊ូ កន្សែងជូតដៃ និងក្រដាសអនាម័យមានដាក់ឱ្យប្រើប្រាស់គ្រប់ពេលវេលា

### តំលៃ:

**$ - $$**

$ តំលៃទាប
$$ តំលៃមធ្យម
$$$ តំលៃខ្ពស់


អង្គការ
ពលកម្ម
អន្តរជាតិ

ប្រសិនបើលោកអ្នកមានសំនួរ សូមទាក់ទងមកអង្គការពលកម្មអន្តរជាតិតាមរយៈអ៊ីម៉េល betterfactories@ilo.org